**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

លេខ ៖ ..១៣.១.១.....(ក)ព្រ.ទ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង [redacted] ចៅក្រមស៊ើបសួរ និងជាប្រធានសាលាដំបូង ខេត្តកំពត
អមដោយលោក [redacted] ជាក្រឡាបញ្ជី

-បានឃើញ មាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២៤៩, មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៩៦ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តកំពត ។

*<u>ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយ ឃើញថា</u>* ៖

១. ឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌មហាវិទ្យាល័យ មុខរបរចូលនិវត្តន៍ ទីកន្លែងកំណើតនៅសង្កាត់៥ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅក្រុម [redacted] ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] "រ" មានកូន៦នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ ទី៣ (ចាស់) មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅក្រុម១០ [redacted] សីហនុ ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] "រ" មានកូន៦នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ មនុស្សឃាតដោយអចេតនា និងបង្កឱ្យមានរបួសដោយ អចេតនា (បាក់រលំអាគារបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស) ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] អុន អត្តលេខ២៦១ និងលោកមេធាវី [redacted] ធារៈ អត្តលេខ១៨៧០T ការិយាល័យសេវាកម្មមេធាវីកម្ពុជា ស្ថិតនៅផ្ទះលេខ២៦៨អឺ ផ្លូវលំ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted]។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ២៤ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ឡែន ភេទប្រុស អាយុ២៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឈើទាល ឃុំជិតូរ៉ែន ស្រុកជុំគិរី ខេត្តកំពត។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល ភេទប្រុស អាយុ៣២ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិ ស្រែផ្អុក ឃុំបន្ទាយមាស ស្រុកបន្ទាយមាស ខេត្តកំពត។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រាំ ភេទស្រី អាយុ១៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឈើទាល កោះចំការ ឃុំសម្បត្តិមានជ័យ ស្រុករមាសហែក ខេត្តស្វាយរៀង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្រៃ ភេទប្រុស កើតឆ្នាំ១៩៨៩ មានទីលំនៅបច្ចុប្បន្ននៅភូមិ កែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ធុន ភេទប្រុស កើតឆ្នាំ១៩៨៥ មានទីលំនៅបច្ចុប្បន្ននៅភូមិ កែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ពេជ្រ ភេទប្រុស កើតឆ្នាំ១៩៨៨ មានទីលំនៅបច្ចុប្បន្ននៅភូមិ កែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហឿន ភេទស្រី អាយុ៤០ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិ៣ ឃុំក្រចាញ ស្រុកបាលុង ខេត្តរតនៈគិរី។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុខ ភេទប្រុស កើតឆ្នាំ១៩៨៨ មានទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

-លោកមេធាវី [redacted], លោកមេធាវី [redacted] ហុង និងលោកមេធាវី [redacted] ភារុំ ជាសមាជិកនៃក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៤នាក់ ដែលមានជនរងគ្រោះ ចំនួន៣៨នាក់ ស្លាប់ចំនួន១៩នាក់ និងរបួសចំនួន១៩នាក់ (តាមបញ្ជីរាយនាមជនរងគ្រោះ)។

-លោកស្រីមេធាវី [redacted]ជាតា ជាសមាជិកនៃក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ដែលមានជនរងគ្រោះចំនួន ០៣នាក់។

<u>អង្គហេតុដើមនៃរឿងនេះមានដូចតទៅ៖</u>

កាលពីអំឡុងឆ្នាំ២០១៩ មានឈ្មោះ[redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងប្រពន្ធឈ្មោះ [redacted]សុធី អាយុ៦១ឆ្នាំ បានរៀបចំអគារស្នាក់នៅរួមដែលមានទំហំប្រមាណកម្ពស់ ៦ជាន់កន្លះ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ដោយម្ចាស់អគារចាប់ផ្តើមសាងសង់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។ បន្ទាប់មកនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ ម្ចាស់អាគារបានធ្វើពាក្យសុំ លិខិតអនុញ្ញាតសាងសង់គោរពជូន ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប។ បន្ទាប់អាជ្ញាធរខេត្តបានចេញលិខិតអនុញ្ញាតសាងសង់មានលេខ ៥២៧/១៩ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ដោយមានអ្នកទទួលម៉ៅការសាងសង់ឈ្មោះ[redacted] វឿន និងឈ្មោះ [redacted] ម៉ៅ ដែលជាវិស្វករ និងទទួលសិក្សាគម្រោងប្លង់អាគារ និងរៀបចំឯកសារសុំច្បាប់អនុញ្ញាតសាងសង់។ ក្នុងពេលសាងសង់ឈ្មោះ [redacted] សារុន បានសាងសង់មុនលិខិតអនុញ្ញាតឲ្យសាងសង់ចេញជាស្ថាពរដោយពុំបានយកក្រុមជាងដែលទទួលម៉ៅការ ដោយឈ្មោះ[redacted] វឿន ទេ គឺបានយកមេជាងសំណង់ឈ្មោះ[redacted]ភាព និងឈ្មោះ គុណ ដែលធ្លាប់ធ្វើការសាងសង់អាគារឲ្យខ្លួន នៅខេត្តព្រះសីហនុកន្លងមក ដោយឲ្យទទួលម៉ៅការសាងសង់តាមដំណាក់កាលនីមួយៗ បើកប្រាក់មួយសប្តាហ៍ម្តង ឯសម្ភារៈសាងសង់គឺម្ចាស់សំណង់ជាអ្នក ទទួលការខុសត្រូវដែលមានកម្មករប្រហែល ៣០នាក់។ ក្នុងរយៈពេលនៃការសាងសង់ នេះនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ មានសមត្ថកិច្ចមន្ត្រីសុរិយោដីខេត្ត បានចុះត្រួតពិនិត្យអាគារដែលទទួលការសាងសង់ដូចមានក្នុង កំណត់ហេតុ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ឃើញថាការសាងសង់ គឺសង់លើសប្លង់ក្រឡាផ្ទៃ និងប្លង់អនុញ្ញាតដោយមានការសង់លើសឡៅតឿ, លើសប្លង់សេ, លើសវេរ៉ង់ដា (អនុញ្ញាតធ្វើ ១,២ម៉ែត្រ ធ្វើលើស ៣តឹក) ខុសប្លង់ជណ្តើរ (ផ្ទើរជើងនិងជណ្តើរយន្ត)។ បន្ទាប់មកសមត្ថកិច្ចសុរិយោដីបានណែនាំឲ្យម្ចាស់អាគារបញ្ឈប់ សកម្មភាពសាងសង់ ដោយតាមការអះអាងរបស់ម្ចាស់អាគារ បានធ្វើបាន៧០% លុះដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] សារុន បានចាក់បេតុងប្លង់សេមួយសន្លឹកនៅជាន់ទី៥។ ក្រោយពីចាក់រួចនៅម៉ោង១៦ និង ២៥នាទី រសៀលនាថ្ងៃ ខែ ឆ្នាំ ខាងលើស្រាប់តែអាគារបាក់រលំតែម្តង បណ្តាលឲ្យមានអ្នកស្លាប់ ៣៦នាក់ និងរបួសធ្ងន់ស្រាលចំនួន ២៣នាក់ ដូចមានរាយឈ្មោះក្នុងតារាងភ្ជាប់មកជាមួយ។ ក្នុងហេតុការខាងលើនេះឈ្មោះ គុណ ដែលជាមេ និងអ្នកបច្ចេកទេសបានស្លាប់ផងដែរ។ ក្រោយកើតហេតុនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ សមត្ថកិច្ចបាន

ឃាត់ខ្លួនម្ចាស់អាគារទាំង ០២នាក់ ឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ រួចបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពតដើម្បីចាត់ការតាមច្បាប់។

## យល់ឃើញថា

-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ គឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារភស្តុតាងនានា ក្នុងសំណុំរឿង ដែលបញ្ជាក់បានថា ជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស មនុស្សឃាតដោយអចេតនា និងបង្កឱ្យមានរបួសដោយអចេតនា (បាក់រលំអាគារបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស) ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ ដូចតាមការប្តឹងចោទប្រកាន់ព្រាកដមែន ។

-តាមរបាយការណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០២០ ឃើញថាការបាក់រលំអាគារនេះបណ្តាលមកពី ការអនុវត្តការងារសាងសង់គ្រឿងផ្គុំសំណង់មិនអនុលោមតាមបទដ្ឋានបច្ចេកទេសដូចខាងក្រោម៖

១. កាត់បន្ថយផ្ទៃមុខកាត់សសរ តូចជាងផ្ទៃមុខកាត់សសរក្នុងប្លង់អនុញ្ញាត គឺពី ០,១៦ ម៉ែត្រការ៉េ មកត្រឹម ០,១២៦ម៉ែត្រការ៉េ។

២. កាត់បន្ថយផ្ទៃមុខកាត់សរសៃដែកសរុបនៃសសរ។

៣. ដោះជន្ទល់ និងក្តារពុម្ពកម្រាលប្លង់សេមុនពេលវេលាកំណត់។

៤. លាយល្បាយបេតុងសម្រាប់សសរ ដោយប្រើប្រាស់ប្រភេទ ស៊ីម៉ងត៍សម្រាប់បូកជញ្ជាំង។

៥. សាងសង់បន្ថែម ឡៀតឿនៅជាន់ផ្ទាល់ដី និងសង់បន្ថែមដំបូលទៃរ៉ាស់។

-អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ មនុស្សឃាតដោយអចេតនា និងបង្កឱ្យមានរបួសដោយអចេតនា (បាក់រលំអាគារបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស) ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃ ទី០៣ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ។

-មានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ពីបទ មនុស្សឃាតដោយអចេតនា និងបង្កឱ្យមានរបួសដោយអចេតនា (បាក់រលំអាគារបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស) ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃ ទី០៣ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ។

-គប្បីរក្សាជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួនមុខតុលាការតាមបញ្ញត្តិមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. បញ្ជូនជនត្រូវចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ពីបទ មនុស្សឃាតដោយអចេតនា និងបង្កឱ្យមានរបួសដោយអចេតនា (បាក់រលំអាគារបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស) ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២០៧ និងមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ និងសំណុំរឿងព្រហ្មទណ្ឌលេខ ២១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ រួមទាំងបញ្ជីរាយនាមជនជាប់ទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងខេត្តកំពត ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ។

២. សម្រេចរក្សាជនត្រូវចោទឈ្មោះ[redacted] សារុន ភេទប្រុស អាយុ៦៥ឆ្នាំ និងឈ្មោះ[redacted] សុធី ភេទស្រី អាយុ៦១ឆ្នាំ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការរហូតដល់ពេលបង្ហាញខ្លួននៅមុខតុលាការ ។

ថ្ងៃចន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កំពត, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០
ចៅក្រមស៊ើបសួរ

[redacted]

ក្រឡាបញ្ជី

[redacted]

បានទទួលដំណឹង
ថ្ងៃចន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កំពត, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០
តំណាងអយ្យការ

[redacted]